ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ស្តីពីការកសាងទំនប់បង្ហៀរទឹកនៅព្រែកកំពង់បាយ ខេត្តកំពត រវាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងក្រុមហ៊ុនវារីអគ្គិសនីកំចាយ Sinohydro




ក្នុងកិច្ចសហប្រតិបត្តិការដ៏រឹងមាំរវាងកម្ពុជា-ចិន ហើយបច្ចុប្បន្ន ដៃគូទាំងពីរបានក្លាយជាមិត្តដែកថែបជាប្រវត្តិសាស្ត្រ តាមរយៈការរិតចំណងមិត្តភាពរវាងថ្នាក់ដឹកនាំ នៃប្រទេសទាំងពីរធ្វេីឲ្យការអនុវត្តគម្រោងអភិវឌ្ឍនិនានា រវាងកម្ពុជា-ចិន ត្រូវធ្វើឡើងជាបន្តបន្ទាប់ ។ ជាក់ស្តែង ដើម្បីរួមចំណែកអភិវឌ្ឍវិស័យទឹកស្អាតនៅកម្ពុជា និងកិច្ចការពារបរិស្ថាន និងសង្គម ក្រុមហ៊ុនវារីអគ្គិសនីកំចាយស៊ីណូហាយដ្រូ (Sinohydro Kamchay Hydroelectric Project Co.,LTD ) បានផ្តល់ជំនួយសាងសង់ទំនប់បង្ហៀរទឹកនៅព្រែកកំពង់បាយ ស្ថិតនៅក្នុងស្រុកទឹកឈូ តំបន់វារីអគ្គិសនីខេត្តកំពត ក្នុងទឹកប្រាក់ចំនួន៨០មុឺនដុល្លារអាមេរិក ។
ដេីម្បីអនុវត្តគម្រោងនេះបាន នៅរសៀលថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ នៅទីស្តីការក្រសួងឧស្សាហកម្មនិងសិប្បកម្ម មានរៀបចំពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាមួយ រវាងឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម ជាមួយលោក Wang Tiefeng នាយកគ្រប់គ្រងទូទៅនៃក្រុមហ៊ុនSinohydro Kamchay

Hydroelectric Project Co.,LTD ។

មានប្រសាសន៍នាឱកាសនោះ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានលើកឡើងពីសារៈសំខាន់នៃមិត្តភាពដ៏ជ្រាលជ្រៅរវាងកម្ពុជា-ចិន និងផលប្រយោជន៍នៃការបង្កើតទំនប់បង្ហៀរទឹកនៅស្រុកកំពង់បាយ ស្រុកទឹកឈូ ដែលជាការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ របស់ប្រមុខរាជរដ្ឋាភិបាលសម្តេចតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដើម្បីទាញប្រភពធុនធានទឹកពីទំនប់វារីអគ្គិសនីកំចាយ ខេត្តកំពតដែលហូរធ្លាក់ចូលសមុទ្រតាមព្រែកកំពង់បាយប្រមាណ១.៧៧០លានម៉ែត្រត្រីគុណ (មួយពាន់ប្រាំពីររយចិតសិបលានម៉ែតត្រីគុណ) ក្នុងមួយឆ្នាំ ស្របពេលដែលតម្រូវការទាញទឹកចូលរោងចក្រផលិតទឹកស្អាតស្ថិតក្នុងសមត្ថភាពត្រឹម ៦ មុឺន ម៉ែត្រត្រីគុណ ក្នុងមួយថ្ងៃ ស្មើនឹង ២២លានម៉ែត្រត្រីគុណ ក្នុងមួយឆ្នាំ ។




ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ សង្ឃឹមថាៈក្រុមហ៊ុន វារីអគ្គិសនីកំចាយនឹងអនុវត្តការងារនេះ បានឆាប់រហ័ស ប្រកបដោយគុណភាព សុវត្ថិភាព សម្រាប់បម្រើផលប្រយោជន៍ដល់វិស័យទឹកស្អាតខេត្តកំពត ដែលកំពុងមានតម្រូវការកើនឡើង ។

លោក Wang Tiefeng នាយកគ្រប់គ្រងទូទៅនៃក្រុមហ៊ុនSinohydro Kamchay Hydroelectric

Project Co.,LTD បានជម្រាបជូនពីមិត្តភាព ដែលចាត់ទុកជាសហគមន៍រួមវាសនាតែមួយ ដែលបានស្តែងចេញតាមរយៈនៃថ្នាក់ដឹកនាំប្រទេសទាំងពីរ ។ ដូច្នេះក្រុមហ៊ុនលោកនឹងប្តេជ្ញាចិត្តសាងសង់ទំនប់បង្ហៀរនេះឲ្យបានរួចរាល់នាពេលខាងមុខ ដើម្បីជាប្រយោជន៍បម្រើវិស័យទឹកស្អាតនៅខេត្តកំពត ស្របតាមតម្រូវការប្រជាពលរដ្ឋនិងទស្សនៈវិស័យរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ។




សូមបញ្ជាក់ថាះបន្ទាប់ពីទំនប់បង្ហៀរទី១ អនុវត្តដោយក្រុមហ៊ុនវារីអគ្គិសនី Sinohydro ត្រូវបានសាងសង់រួច ការសាងសង់ទំនប់បង្ហៀរទី២ នៅផ្នែកខាងក្រោម នឹងត្រូវពិនិត្យលទ្ធភាពបន្តទៀតដែលត្រូវប្រើប្រាស់ដោយថវិការបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីប្រើប្រាស់ឲ្យអស់លទ្ធភាព និងសក្តានុពលនៃប្រភពធុនធានទឹកដែលយើងមាន ដោយឈរលើកិច្ចការពារបរិស្ថាន និងផលប៉ះពាល់សង្គមខ្ពស់ ។